គម្រោងបច្ចេកទេសជំនួយដល់ការពង្រឹង

ផលិតភាព ជុំវិញតំបន់ទន្លេសាប

TSTD (ADB TA 7305-CAM)

# បច្ចេកទេសចិញ្ចឹមត្រីចម្រុះ



## ទីតាំងទំនាក់ទំនងទិញកូនត្រីពូជ

**ខេត្តកំពង់ចាម**
- បាធាយៈ ញ៉ៀម ពេញ ០៨៨ ៩០ ១០ ៤៩៦
- ជើងព្រៃៈ អ៊ុន ប៉ុក ០៩៧ ៣០ ៥២ ៣៩១

**ខេត្តកំពង់ធំ**
- ស្ទឹងសែនៈ កង សម្បត្ត ០១៧ ២៧ ២២ ៨៧
- ស្ទោងៈ គឹង គា ០៩២ ៦៨ ៩២ ៥៧

**ខេត្តបន្ទាយមានជ័យ**
- សិរិសោភ័ណ្ឌៈ គាត សុណាន ០៨៨៩១៥៧៦៦១

ស្រុកអូរជ្រៅៈ យឹម ភាត់ ០៨៩ ៦៤ ០៨ ៥៨

**ខេត្តសៀមរាប**
- សូទ្រនិគមៈ ស៊ាយ ប៉ុក ០៨៨ ៥៩៩ ៧០ ៩៧
- សៀមរាបៈ សេង អាន ០៩៦ ២៦៣ ៥៧ ៥៧

ឧបត្ថម្ភថវិកាដោយៈ

រដ្ឋាភិបាលប្រទេសហ្វាំងឡង់ និង ធនាគារអភិវឌ្ឍន៍អាស៊ី

ខែ មេសា ឆ្នាំ ២០១៣

## សេចក្តីផ្តើម

ការចិញ្ចឹមត្រីចម្រុះក្នុងស្រះ គឺជារបៀបចិញ្ចឹមមួយដែល ធ្វើឱ្យអ្នកចិញ្ចឹម បានចំណេញច្រើន ដោយសារចំណី ដែលបានផ្តល់ឱ្យត្រី ត្រូវបានត្រីពីរ ឬ ច្រើនប្រភេទ ស៊ីអស់ ព្រោះប្រភេទត្រីបានជ្រើសរើសចិញ្ចឹម មានចរឹតស៊ីចំណី ខុសៗគ្នា គឺថា ត្រីប្រភេទខុសគ្នា ស៊ីចំណីនៅស្រទាប់ទឹក ខុសគ្នា និង ស៊ីចំណីប្រភេទខុសគ្នា។

ជាទូទៅ ប្រភេទត្រីដែលគេចិញ្ចឹមចម្រុះភាគច្រើន ជាប្រភេទត្រី ដែលស៊ីទាំងចំណីធម្មជាតិ និង ចំណីបន្ថែម ។ ត្រីទាំងនេះ មាន ត្រីឆ្ពិន ត្រីទីឡាព្យា ត្រីព្រលូង ត្រីកាប...។

## គុណសម្បត្តិនៃការចិញ្ចឹមត្រីចម្រុះ

✧ប្រើចំណីបន្ថែមអស់តិច បានផលត្រីច្រើន ដោយសារ មានប្រភេទត្រីមួយចំនួន ស៊ីចំណីធម្មជាតិដែលជានិច្ចកាល តែងតែកើតមានក្នុងទឹក។

✧ធ្វើឱ្យទឹកស្រះរក្សាគុណភាពល្អបានយូរ ព្រោះប្រភេទ ត្រីចម្រុះ បានស៊ីអស់លទ្ធភាពនូវចំណីដែលបានផ្តល់ឱ្យ ដែលជាហេតុធ្វើឱ្យទឹក មិនងាយស្អុយ។

✧ការចិញ្ចឹមត្រីចម្រុះ ផ្តល់ភាពសមស្រមច្រើនសម្រាប់ កសិករដែលមិនសូវមានលទ្ធភាពទិញចំណី បានគ្រប់គ្រាន់ និង មិនមានលទ្ធភាពផ្លាស់ប្តូរទឹក។



## តើត្រូវការបច្ចេកទេសអ្វីខ្លះដើម្បីទទួលបានជោគជ័យ ?

### ១. ការកំណត់លក្ខណៈសម្បត្តិនៃស្រះ

✧នៅជិតប្រភពទឹក ឬជាស្រះដែលមិនរីងទឹកនៅរដូវប្រាំង

✧មានភ្លឺស្រះព័ទ្ធជុំវិញ ជានាមិនលិចទឹកនៅរដូវវស្សា

✧នៅជិតផ្ទះ និង មានផ្លូវចេញចូល ស្រួល។



### ២. ការរៀបចំស្រះ មុនដាក់ត្រីចិញ្ចឹម

➢បាំងស្បៃនីឡុងជុំវិញស្រះការពារសត្រូវរបស់ត្រីចូលស្រះ

➢បូមទឹកពង្រីងស្រះ និង បាចភក់ចេញ បើទុកភក់ យ៉ាងច្រើន ត្រឹមកំពស់ ២០ សង់ទីម៉ែត្រ (២ តឹក)។

➢បាចកំបោរស ចំនួន ពី៥ ទៅ ៧គីឡូក្រាមក្នុង១០០ម²។ ទុកស្រះ រយៈពេលពី២ ទៅ៣ថ្ងៃ បន្ទាប់មកទើបបញ្ចូល ទឹកជម្រៅ ១ ភាគ ៣ នៃជម្រៅស្រះ។

➢ដាក់ជីលាមកគោក្របីចំនួនពី៣០ទៅ៥០គីឡូ/១០០ម²

☞ឬ លាមកមាន់/ទា ចំនួន ១០ - ១៥គីឡូ/១០០ម²

☞ឬ ជីកំប៉ុស្តិ៍ ចំនួន ពី ៣០ - ៥០គីឡូ/១០០ម²

➢ដាក់ជីអ៊ុយរេ ឬ ដេ អា ប៉េ ចំនួន ០,៥គីឡូ/១០០ម²

➢បន្ទាប់មកបញ្ចូលទឹកឱ្យពេញស្រះ ហើយទុករយៈពេល ពី៤ ទៅ ៥ថ្ងៃ សិន ទើបដាក់កូនត្រីចិញ្ចឹម។



## ៣. ដង់ស៊ីតេកូនត្រីដាក់ចិញ្ចឹម និង របៀបចិញ្ចឹម

✧បែបយថាកម្ម: ដាក់កូន ១ក្បាល ក្នុង ១ម$^{២}$ ។ ការចិញ្ចឹមបែបនេះ គឺ មិនចាំបាច់ឱ្យចំណីបន្ថែមទេ។

✧បែបពាក់កណ្តាលប្រពលវប្បកម្ម: ដាក់កូនពី ៣ ទៅ ៥ ក្បាលក្នុង ១ម$^{២}$។ ចិញ្ចឹមបែបនេះ គឺ ត្រូវឱ្យចំណីបន្ថែម។

✧បែបប្រពលវប្បកម្ម: ដាក់កូនច្រើនជាង៥ក្បាលក្នុ១ម$^{២}$។ ការចិញ្ចឹមបែបនេះ ត្រូវឱ្យចំណីបន្ថែម និង ប្រើបច្ចេកទេសចិញ្ចឹមកម្រិតខ្ពស់។

## ៤. របៀបព្រលែងកូនត្រី

☼ ការព្រលែងកូនត្រី គួរធ្វើពេលត្រជាក់ គឺព្រឹក ឬ ល្ងាច។

☼ មុនព្រលែង ត្រូវត្រាំថង់កូនត្រីក្នុងទឹកស្រះ រយៈពេលពី១៥ ទៅ២០នាទីដើម្បីឱ្យមានលំនឹងសីតុណ្ហភាពរវាងទឹកក្នុងថង់ និង ទឹកក្នុងស្រះ។

☼បន្ទាប់មក ស្រាយមាត់ថង់ហើយបាចទឹកស្រះចូលថង់ម្តងបន្តិចៗដោយពន្ទិចមាត់ថង់បន្តិច ទុកពេលឱ្យកូនត្រីហែលចេញអស់ពីថង់។ ការធ្វើបែបនេះគឺធ្វើឱ្យកូនត្រីអាចបន្សាំខ្លួនបាននឹង pH (មជ្ឈដ្ឋានជូរ)របស់ទឹក។





## ៥. ប្រភេទចំណី និង របៀបផ្តល់ចំណី

✧<u>ចំណីធម្មជាតិ:</u> ចំណីធម្មជាតិមាន ២ ប្រភេទគឺ៖ ហ្វីតូប្លង់តុង (រុក្ខជាតិល្អិតៗក្នុងទឹក)និង ហ្សូប្លង់តុង(សត្វល្អិតតូចៗក្នុងទឹក) ។ យើងអាចបង្កើនចំណីធម្មជាតិបាន ដោយដាក់ជីលាមកសត្វ ជីគីមី ឬ ជីកំប៉ុស្តិ៍ ក្នុងទឹកស្រះ។ យើងអាចសំគាល់បរិមាណចំណីធម្មជាតិក្នុងទឹកស្រះបានដោយសំគាល់មើលពណ៌នៃទឹកស្រះ ។ បើទឹកមានពណ៌បៃតងចាស់ បញ្ជាក់ថាទឹកស្រះ មានចំណីធម្មជាតិគ្រប់គ្រាន់។ តែបើទឹកស្រះ មានពណ៌ថ្លាពេក បញ្ជាក់ថាទឹកស្រះមិនសូវមានចំណីធម្មជាតិទេ។ ដូច្នេះរៀងរាល់ ១៥ ថ្ងៃម្តងគួរដាក់៖

- ជីលាមកគោ-ក្របី ចំនួន ពី១០ ទៅ១៥គីឡូក្នុង១០០ម$^{២}$
- ឬ ជីគីមី ចំនួនពី ០,២ ទៅ០,៣ គីឡូ ក្នុងផ្ទៃស្រះ១០០ម$^{២}$



✧ <u>ចំណីបន្ថែម:</u> មានដូចជា កន្ទក់ ពោត សណ្តែក ចុងអង្ករ ម្សៅត្រី ចំណីគ្រាប់ កាកសំណល់ផ្ទះបាយ បន្លែ ។ ពោត សណ្តែក ចុងអង្ករ ត្រូវចំអិនឱ្យបានឆ្អិនល្អ ហើយទុកឱ្យត្រជាក់សិន ទើបលាយជាមួយបន្ទក់ ដើម្បីរក្សាជាតិវីតាមីនដែលមានក្នុងកន្ទក់។



### របៀបដាក់ចំណីបន្ថែម

- ដាក់ចំណីក្នុងកញ្ច្រែង ពន្លិចក្នុងទឹកប្រហែល០,៥ម៉ែត្រ
- ដាក់ចំណីពី២ ទៅ៣កន្លែង ក្នុងស្រះតែមួយ។
- ឱ្យចំណីត្រី ពី១ ទៅ ២ ដង ក្នុង១ថ្ងៃ ក្នុងបរិមាណពី៣ ទៅ ៥ភាគរយ នៃទម្ងន់ដងខ្លួនសរុប របស់ត្រី។

## ៦. ការគ្រប់គ្រងស្រះត្រី ក្រោយដាក់កូនចិញ្ចឹម

- កាប់សំអាតស្មៅជុំវិញស្រះនិងនៅក្នុងស្រះ ឬ អាចទុកយ៉ាងច្រើន ត្រឹម ១ ភាគ ៣ នៃផ្ទៃស្រះ។
- ឧស្សាហ៍ផ្លាស់ប្តូរទឹករៀងរាល់មួយខែម្តង និងរក្សាកំពស់ទឹកយ៉ាងតិច ជម្រៅ ១ម៉ែត្រ។
- ពិនិត្យមើលស្រះ បើឃើញមានវត្តមានត្រីកាចក្នុស្រះ ត្រូវរកមធ្យោបាយចាប់ ឬ កំចាត់វាចេញ។
- នៅពេលព្រឹកព្រលឹម បើឃើញត្រីងើបលើផ្ទៃទឹក ត្រូវផ្លាស់ប្តូរទឹក ឬ បន្ថែមទឹក ។

## ៧. ការប្រមូលផល

- គួរផ្អាកការដាក់ជីគ្រប់ប្រភេទ១០ថ្ងៃមុន ប្រមូលផល
- គួរលៃពេលប្រមូលផលឱ្យចំពេលត្រីមានតំលៃខ្ពស់ ដែលជាទូទៅនៅខែមិថុនា កក្កដា និង សីហា។






<u>រៀបចំដោយ:</u> លោក សៀវ សៅភាគ្យ

អ្នកជំនាញផ្នែកវារីវប្បកម្ម (TSTD)

saopheak@gmail.com

<u>ព័ត៌មានបច្ចេកទេសផ្សេងទៀត</u>: www.telecentercambodia.org/